ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១០៥ . អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកាត់ចេញពីផែនទីតម្រូវព្រៃឈើបម្រុងទុកអចិន្ត្រៃយ៍របស់រដ្ឋ និងការធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ និងការធ្វើប្រទានកម្មដីចំនួន ២៥២ ហិកតា ជូនប្រជាពលរដ្ឋកាន់កាប់

---

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីព្រៃឈើ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាល នៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ ៨៨ អនក្រ.បក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០០ ស្តីពីការបង្កើតក្រុមប្រឹក្សាគោលនយោបាយដីធ្លី
- បានឃើញអនុក្រឹត្យលេខ ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ

- បានឃើញអនុក្រឹត្យលេខ ១៤៦ អនក្រ.បក ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០០៥ ស្ដីពីសម្បទានដីសេដ្ឋកិច្ច
- បានឃើញសារាចរ ០២ សរ ចុះថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ១៩៩៥ ស្ដីពីការប្រឡងប្រណាំងកែលំអសោភ័ណភាពខេត្តទូទាំងប្រទេស
- បានឃើញសារាចរលេខ ០៥ សរ ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០០០ របស់រាជរដ្ឋាភិបាលស្ដីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភនៅក្នុងព្រះរាជាណាចក្រកម្ពុជា
- បានឃើញសារាចរលេខ ០២ សរ ចុះថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០០៥ ស្ដីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់
- បានឃើញរបាយការណ៍លេខ ៩៧ របក ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១២ របស់អភិបាលនៃគណៈអភិបាលខេត្ត និងជាប្រធានគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពត
- តាមសំណើលេខ ១០៦ លស ថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១២ របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពត
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**មាត្រា ១ ៖**

ត្រូវបានកាត់ចេញពីផែនទីគម្របព្រៃឈើបម្រុងទុកអចិន្ត្រៃយ៍ឆ្នាំ ២០០២ និងធ្វើអនុបយោគមកជាដីឯកជនរបស់រដ្ឋ នូវផ្ទៃដីចំនួន ២៥២ ហ.ត( ពីររយហាសិបពីរហិកតា) ស្ថិតនៅក្នុងភូមិត្រពាំងថ្ម ឃុំល្បើក ស្រុកឈូក ខេត្តកំពត ដែលកំណត់តាមប្រពន្ធ័កូអរដោណេ Project UTM Zone 48N Datum wgs 84 ដូចក្នុងផែនទី និងចំណុចគោលនៃក្បាលដីនីមួយៗមានភ្ជាប់ក្នុងឧបសម្ពន្ធ័ I និង II នៃអនុក្រឹត្យនេះ និងដែលមាននិយាមកាដូចខាងក្រោម ៖

| ចំណុច | X | Y | ចំណុច | X | Y | ចំណុច | X | Y |
|---|---|---|---|---|---|---|---|---|
| 1 | 420886 | 1195805 | 7 | 422117 | 1195453 | 12 | 420638 | 1194819 |
| 2 | 420962 | 1195765 | 8 | 422799 | 1195001 | 13 | 420891 | 1194932 |
| 3 | 421215 | 1195693 | 9 | 421175 | 1193770 | 15 | 420789 | 1195515 |
| 4 | 421658 | 1195588 | 10 | 420660 | 1194069 | | | |
| 5 | 421719 | 1195574 | 11 | 420587 | 1194464 | | | |

**មាត្រា ២ ៖**

ត្រូវបានប្រគល់អាណត្តិកាន់កាប់ និងបែងចែកដីឯកជនរបស់រដ្ឋដូចមានចែងក្នុងមាត្រា ១ ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពតធ្វើការគ្រប់គ្រង និងធ្វើប្រទានកម្មផ្ដល់ជូនប្រជាពលរដ្ឋចំនួន ១៩១ (មួយរយសែសិបមួយ) គ្រួសារ ដែលបានកាន់កាប់និងប្រើប្រាស់ដីនោះ ដើម្បីមានសិទ្ធិកាន់កាប់ស្របច្បាប់ទៅតាមទំហំដីជាក់ស្ដែង ដែលគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋ និងរដ្ឋបាលសុរិយោដីបានធ្វើការអង្កេត និងវាស់វែងស្របតាមនីតិវិធីនៃអនុក្រឹត្យលេខ ១១៨ អនក្រ.បក ស្ដីពីការគ្រប់គ្រងដីរដ្ឋ និងអនុក្រឹត្យទាក់ទងនឹងការងារចុះបញ្ជីដីធ្លី។

ក្នុងពេលដំណើរការវាស់វែងនិងបែងចែកដីជាក់ស្ដែង គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តត្រូវគិតបញ្ចូល និងកាត់ចេញនូវចំណែកដីមួយចំនួនដែលនឹងត្រូវរក្សាទុក សម្រាប់ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាធារណៈ និងសង្គមក្នុងមូលដ្ឋានផ្ទាល់ ។

**មាត្រា ៣ ៖**

ក្នុងពេលរង់ចាំដំណើរការចុះបញ្ជីដីធ្លីតាមនីតិវិធីបានបញ្ចប់ជាស្ថាពរ គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពតត្រូវផ្ដល់ប័ណ្ណកម្មសិទ្ធិបឋមលើដីនោះ ដូចមានគម្រូក្នុងឧបសម្ព័ន្ធ III នៃអនុ

ក្រឹត្យនេះ ដល់ប្រជាពលរដ្ឋដែលទទួលបានដី ក្នុងនោះត្រូវធ្វើប្រទានកម្មជាកម្មសិទ្ធិឯកជន លើចំណែកដីមិនលើសពី ០៥ (ប្រាំ) ហិកតា លើកលែងតែដីដែលបានដាំដំណាំរួច ដូចជាកៅស៊ូជាដើម អាចផ្ដល់ជាកម្មសិទ្ធិឯកជន ក្នុងទំហំមិនលើសពី ២០០ (ពីររយហិកតា) ។

**មាត្រា ៤ ៖**

ចំណែកដីនៅសល់ពីការធ្វើប្រទានកម្មដូចចែងក្នុងមាត្រា ៣ ត្រូវចុះបញ្ជីជាដីឯកជនរបស់រដ្ឋ ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពត និងអាចផ្ដល់ប្រទានកម្មនូវសិទ្ធិសម្បទានដីសេដ្ឋកិច្ចខ្នាតតូច ដោយត្រូវផ្ដល់លិខិតបញ្ជាក់ការប្រើប្រាស់ដីរដ្ឋក្នុងរូបភាពសម្បទានដីសេដ្ឋកិច្ចខ្នាតតូច ដូចមានគម្រូក្នុងឧបសម្ព័ន្ធទី IV នៃអនុក្រឹត្យនេះ នៅក្នុងពេលរង់ចាំការចុះកិច្ចសន្យាសម្បទានដីសេដ្ឋកិច្ចជាផ្លូវការ ។

**មាត្រា ៥ ៖**

កម្រៃសេវាសុរិយោដី និងកាតព្វកិច្ចពន្ធផ្សេងៗដែលមានជាប់ពាក់ព័ន្ធជាបន្ទុករបស់រដ្ឋ។

**មាត្រា ៦ ៖**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយពីអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍។

**មាត្រា ៧ ៖**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តកំពត ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី ១៧ ខែ[illegible] ឆ្នាំ ២០១២

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល៖

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី
- ខុទ្ទកាល័យ នាយករដ្ឋមន្ត្រី
- ដូចមាត្រា ៧
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ ១០៥.អនក្រ.បក ចុះថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ២០១២**

**ស្តីពី ការកាត់ចេញពីដែនដីគម្របព្រៃឈើបម្រុងទុកអចិន្ត្រៃយ៍របស់រដ្ឋ និង ធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ**

**និងការធ្វើប្រទានកម្មដីចំនួន ២៥២ ហិកតា ជូនប្រជាពលរដ្ឋកាន់កាប់ប្រើប្រាស់**




| ចំណុច | X | Y |
|---|---|---|
| 1 | 420886 | 1195805 |
| 2 | 420962 | 1195765 |
| 3 | 421215 | 1195693 |
| 4 | 421658 | 1195588 |
| 5 | 421719 | 1195574 |
| 7 | 422117 | 1195453 |
| 8 | 422799 | 1195001 |
| 9 | 421175 | 1193770 |
| 10 | 420660 | 1194069 |
| 11 | 420587 | 1194464 |
| 12 | 420638 | 1194819 |
| 13 | 420891 | 1194932 |
| 15 | 420789 | 1195515 |